# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨៣ ស្ដីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ តៅ ទ្រី ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធ នឹងជម្ងឺអេដស៍ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៧១១

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨៦ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ,ឧកញ៉ា និង អស់លោក ចំនួន ០៨ រូប ៧៧១២

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨៧ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកឧកញ៉ា និង អស់លោក ចំនួន ២៧ រូប ៧៧១៣

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨៨ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម ចំនួន ០២ រូប ៧៧១៥

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨៩ ស្ដីពីការតែងតាំងឥស្សរជន ចំនួន ១១ រូប ជាអនុប្រធានសមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ៧៧១៦

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៩០ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ជានាយទាហានជាន់ខ្ពស់ ចំនួន ២៧ រូប ៧៧១៨

១៤-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៩៤ ស្ដីពីការបញ្ចប់មុខតំណែងឯកឧត្តម ជាទីប្រឹក្សា និង ទីប្រឹក្សាអមក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំនួន ០៧ រូប ៧៧១៩

១៥-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៩៥ ស្ដីពីការតម្លើង ឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូន ឯកឧត្តម ង៉ែ ប៊ុនឈឿន ពីឋានន្តរស័ក្តិ វរមន្ត្រីថ្នាក់លេខ ៧ ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ១ ជាករណីពិសេស ៧៧២០

១៥-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៩៩ ស្ដីពីការតម្លើងឋានៈស្មើ អគ្គនាយក ជូនឯកឧត្តម អ៊ឹម តុច នាយកវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និង កីឡា ៧៧២១

១៥-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០១ ស្ដីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី ផន សុគ័ត្រ ជាទីប្រឹក្សា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៧២២

១៥-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០២ ស្ដីពីការតែងតាំងឯកឧត្តម ស ឆារិទ្ធ ជាទីប្រឹក្សា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៧៧២៣

១៥-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៣ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក WANG JINSONG នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ៧៧២៤
១៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម.លោកជំទាវ.លោកស្រី និង អស់លោក ចំនួន ១៩ រូប ៧៧២៥
១៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម.លោកជំទាវ និង អស់លោក ចំនួន ២២ រូប ៧៧២៦

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៧៨ អនក្រ.បក ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និង មន្ត្រីនគរបាលជាតិ ៧៧២៧
១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៧៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៧៣០
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៨០ អនក្រ.បក ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និង ការដាក់ស្លាកសញ្ញាសារធាតុគីមី ៧៧៣២
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៨១ អនក្រ.បក ស្តីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី ៧៧៤៧
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤១ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៧៧៥១
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៧៥២
១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៧៥៣
១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៧៥៤
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៥ អនក្រ.តត ស្តីពីការតម្លើងថ្នាក់មន្ត្រីរាជការ ៧៧៥៥
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៦ អនក្រ.តត ស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ៧៧៦៦
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤៧ អនក្រ.តត ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ និង ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម តាមលក្ខន្តិកៈដោយឡែក ៧៧៦៨

## III. ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ធនធាន អ៊ីមផត អិចផត ៧៧៧២
២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ព្រៀស ដាម (ខេមបូឌា) ៧៧៧៤

១៥-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៣ ស្ដីពីការប្រោសព្រះរាជទាន ចំពោះលោក WANG JINSONG នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ៧៧២៤
១៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៤ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,លោកជំទាវ,លោកស្រី និង អស់លោក ចំនួន ១៥ រូប ៧៧២៥
១៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០០៥ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,លោកជំទាវ និង អស់លោក ចំនួន ២២ រូប ៧៧២៦

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៧៨ អនក្រ.បក ស្ដីពីការសម្រួលការផ្ដល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និង មន្ត្រីនគរបាលជាតិ ៧៧២៧
១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៧៩ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៧៧៣០
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៨០ អនក្រ.បក ស្ដីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និង ការដាក់ស្លាកសញ្ញាសារធាតុគីមី ៧៧៣២
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៨១ អនក្រ.បក ស្ដីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី ៧៧៤៧
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤១ អនក្រ.តត ស្ដីពីការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៧៧៥១
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៧៥២
១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៧៥៣
១៩-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៧៥៤
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤៥ អនក្រ.តត ស្ដីពីការតម្លើងថ្នាក់មន្ត្រីរាជការ ៧៧៥៥
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤៦ អនក្រ.តត ស្ដីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ៧៧៦៦
២០-១០-២០០៩ -អនុក្រឹត្យលេខ ១៥៤៧ អនក្រ.តត ស្ដីពីការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ និង ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម តាមលក្ខន្តិកៈដោយឡែក ៧៧៦៨

## III.ការងារបណ្ដាក្រសួង

### ទីស្ដីការក្រសួងមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឆនឆាន អ៊ីមផត អិចផត ៧៧៧២
២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ម្រេស ផាម (ខេមបូឌា) ៧៧៧៤

# ត

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សិនទ្រិត ឌីស្ត្រីប៊ូសិន** ៧៧៧៦

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីហ្សុី ស្មាល (ខេមបូឌា)** ៧៧៧៨

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៣៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ែនបូហ៊ឺល ខបតើរេសិន អិលធីឌី** ៧៧៨០

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៤១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេនតូ អ៊ីមផត អិចផត** ៧៧៨២

២១-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៤៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេតូត្រេដ (ខេមបូឌា) អិលធីឌី** ៧៧៨៤

២១-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៤៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អមព គាន ស្ប៉ា** ៧៧៨៦

២២-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣៤៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូ ស៊ី ធី អេស អ៊ីម-អិចផត** ៧៧៨៨

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ /ជម្ងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ទោ វេជ្ជបណ្ឌិត **កៅ ឆ្វី** អត្តលេខ ០០០២៥៧ ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធ នឹងជម្ងឺអេដស៍ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

៣៧៧.០៩១០.១០០០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៩*

លេខ:៩៤២១ ច.ល
ថតចម្លងដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩
អគ្គនាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
ទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុំ ម៉ៅ ប៊ុនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ

១- ឯកឧត្តម ឡោក ហ៊ួរ

២- លោកជំទាវ ឆោម សោភ័ណ្ឌី

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១- ឯកឧត្តម ហាញ់ ចំរើន

២- ឯកឧត្តម តោ វីរូ

៣- ឯកឧត្តម ឃឹម ស៊ុនសូដា

៤- ឯកឧត្តម លឹម ហ៊ួរនីតា

៥- លោក ឡុង សុភីន

គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្ញទ្ធិ

- ឧកញ៉ា លឹម ហ៊ួរនីតូ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៖ល. ០៩១០. ១០០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩

លេខៈ ៩៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៩
...ការអនុរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាសិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម **គីម សុវណ្ណ**

២- លោក **កែវ សែន**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម ឧកញ៉ា **នួន វណ្ណឌី**

២- លោកវរសេនីយ៍ឯក **លឹម វុឌ្ឍិន**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម **ស្រ៊ុន គុន្ធុល**

២- ឯកឧត្តម **ហម សារាវុធ**

៣- លោកឧកញ៉ា **ហងរ្ស ស៊ីផា**

៤- ឯកឧត្តម **លី អ៊ុតលី**

៥- លោក **យឿម ម៉ាន់**

៦- លោក **យឿម គង់**

៧- លោក **សឿ ប៊ុនណ្ណា**

៨- លោក **ម៉ែន សោភ័ណ**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- លោក **សែន វ៉ាន់ណាក់**

២- លោក **ហេង សុខហ៊ន**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- លោក ទ៉េត រិន

៤- លោក ខូន ធនលាភ

៥- លោក ចេង មុន្នីរត្ន

៦- លោក ង៉ែ គា

៧- លោក ថោង ចំនួសុម៉ា

៨- លោក ហ៊ួត ឈួរ

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា ចំពោះ :

១- លោក ស៊ួ ហ៊ុរ

២- លោក អ៊ួង ចាន់រិទ្ធិ

៣- លោក ប៉ើន បុញ្ញាវិសុទ្ធ

៤- លោក សំ ដេត

៥- លោក សោម ផល្លី

៦- លោក គុល វិបុល

៧- លោក ជួប សុគារ៉ា

នស/រកត.១០០៩.១០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩*

លេខៈ ៩៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ ១០ ឆ្នាំ២០០៩

...ធិការរាជរដ្ឋាភិបាល

ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

ឯកឧត្តម ផៃ សុខខេង

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

ឯកឧត្តម សំ រិទ្ធី

៣រ៧.០៩១០.១០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩

លេខៈ ៩៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេង

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០២០៩ / ១៧៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានតែងតាំងឥស្សរជនចំនួន ១១រូប ជាអនុប្រធាន សមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចមានរាយនាមខាងក្រោម ៖

**ក. សមាសភាពអនុប្រធាន និងសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៖**

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | ទី យ៉ាវ | អនុប្រធាន | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២. | ឯកឧត្តម | ឃិន ពុំមីការ | សមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣. | ឯកឧត្តម | រស់ ធល | សមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៤. | ឯកឧត្តម | សួស តិកង្សៀប | សមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៥. | ឯកឧត្តម | ស៊ុយ ថេងឈួង | សមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៦. | ឯកឧត្តម | នៅ បោនន័រ | សមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៧. | លោកជំទាវ | វៀល បូរី | សមាជិកា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

៨. ឯកឧត្តម យឹម សារី សមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៩. ឯកឧត្តម ឡុង ឈាង សមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**ខ. សមាជិកមិនអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ :**

១. ឯកឧត្តម ស្រ៊ុន ពារា សមាជិក មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២. ឯកឧត្តម ផាត់ លេង សមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៩៧.០៩១០.១០០៦ **ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩* លេខៈ ៩៤៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៥០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

**ក_គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍** ចំពោះ :-

-ឧត្តមសេនីយ៍ទោ អ៊ុច ម៉ាន់ថា ០០០៤៥១

**ខ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា** ចំពោះ :-

១-ឧត្តមសេនីយ៍ទោ គង់ ម៉ក់ ០០០៧៥០ ២-ឧត្តមសេនីយ៍ទោ ម៉ាង ចំរើន ០០០៧៥៥

**គ_គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ** ចំពោះ :-

១- វរសេនីយ៍ឯក ស៊ុំ សិទ្ធី ០០២០៥២ ៣- វរសេនីយ៍ទោ យក់ យុទ្ធនារា ០០៨៨៤៧
២- វរសេនីយ៍ទោ ឡឹក ផាន់ណា ០៥០២៥៩

**ឃ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ** ចំពោះ :-

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | សៅ សារិ | ០០២១៥៥ | ១២ | វរសេនីយ៍ត្រី | សុខ សុផាត | ០០៩៥៤៨ |
| ២ | វរសេនីយ៍ឯក | ហ៊ិន សារ៉េត | ០០០៩៤០ | ១៣ | វរសេនីយ៍ត្រី | ហ៊ុល ទុន្នី | ០២៧៧៣៨ |
| ៣ | វរសេនីយ៍ទោ | ជួន សុភឿន | ០០៩៥៦៧ | ១៤ | វរសេនីយ៍ត្រី | នឹម សាខុន | ០២៤៤៤៩ |
| ៤ | វរសេនីយ៍ទោ | ចាន់ សាន្ត | ០០១០៧៦ | ១៥ | វរសេនីយ៍ត្រី | នូ សុវណ្ណា | ០១៧៦១០ |
| ៥ | វរសេនីយ៍ទោ | និត្យ សុជាតិ | ០០៩៥៥៨ | ១៦ | វរសេនីយ៍ត្រី | ចាន់ សីលក្ខំ | ០០៩៥៤៥ |
| ៦ | វរសេនីយ៍ទោ | គោគ សារ៉ន | ០០៩៥៥១ | ១៧ | វរសេនីយ៍ត្រី | ហោ យ៉ុន | ០១៧៦១៩ |
| ៧ | វរសេនីយ៍ទោ | សូ វណ្ណារ៉ា | ០០២០៨៤ | ១៨ | វរសេនីយ៍ត្រី | ជាង សុខុម | ០១៧៦១៨ |
| ៨ | វរសេនីយ៍ទោ | អឿន ប៊ុច | ០១៧៦១៥ | ១៩ | វរសេនីយ៍ត្រី | យ៉ាន គា | ០១៧៦១៦ |
| ៩ | វរសេនីយ៍ទោ | ម៉ឹម សារិទ្ធ | ០០៩៥៦៣ | ២០ | វរសេនីយ៍ត្រី | ចាន់ សុផល | ០១៧៦០១ |
| ១០ | វរសេនីយ៍ត្រី | គង់ ប៊ូ | ០១៣០៥៤ | ២១ | វរសេនីយ៍ត្រី | តុល ផល | ០១៧៦០៧ |
| ១១ | វរសេនីយ៍ត្រី | មុំ ហឿន | ០១៧៦១៥ | | | | |

៣រ៧. ០៩១០.២០០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៩២៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

**ព្រះរាជក្រឹត្យ**

នស/រកត/១០០៥/៩៦៤

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៤/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** បញ្ចប់មុខតំណែងឯកឧត្ដម ជាទីប្រឹក្សា និងទីប្រឹក្សាអមក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈចំនួន ០៧ រូប ដូចមានរាយនាមខាងក្រោមៈ

១-ឯកឧត្ដម ហ៊ូ វុឌ្ឍី
២- ឯកឧត្ដម អ៊ុក សមវិទ្យា
៣- ឯកឧត្ដម គីប អឿន
៤- ឯកឧត្ដម ម៉ែន សុចិត្រ
៥- ឯកឧត្ដម ជូរ អៀងលី
៦- ឯកឧត្ដម សួន វីដា
៧- ឯកឧត្ដម សួង ម៉េងឡុង

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣រល.០៩១០.១០១១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥*

លេខៈ៩៣៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ ១០ ឆ្នាំ២០០៥
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
ឃឹម ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើង **ឋានន្តរស័ក្តិ ឧត្តមមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូន : **ឯកឧត្តម ង៉ែ ម៉ុនឈឿន** ពី ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ១ ជាករណីពិសេស ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ប.ម.ល. ០៩១០.១០១២

លេខ:៩៣៧ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ចិនគេង**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៩៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានៈស្មើ **អគ្គនាយក** ជូនឯកឧត្តម **អ៊ុំ រុច** នាយកវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៩៧៤ ច.ល

៣៧ល.០៩១០.១០១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០០៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩*

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា វរក្ខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ជិន សុគន្ធា** អត្តលេខ ០១២២៧៦ ជាទីប្រឹក្សាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ: ៩៣០ ច.ល

៣៩៧.០៩១០.២០០៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩*

ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរា ជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំង ឯកឧត្តម **ស នារិន្ទ** ជាទីប្រឹក្សាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ល.០៩១០.១០១៩

លេខ: ៩៣៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ១០ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

លោក WANG JINSONG

នូវ

## គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.០៩១០.១០៧០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩*

លេខៈ ៩៧៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ

១- លោក ប៊ុន ឆារំង ២- លោក យិន ម៉ៅ

៣- លោក ឈឹម តន ៤- លោក ខាន់ ខឡូនៈ

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ

១- ឯកឧត្តមឧកញ៉ា ច័ន្ទ ចណ្ណា ២- លោកជំទាវ គ្រួច រ៉ី ម៉ីត់ ពេជ្ររិទ្ធ

គ-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ចំពោះ

១- ឯកឧត្តមឧត្តមសេនីយឯក យូន យុទ្ធី ២- ឯកឧត្តមឧត្តមសេនីយត្រី ឡាច ម៉ាន់

៣- វរសេនីយឯក ប៉ូល រតនា

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ

១- ឯកឧត្តម ហេង ម៉ាន់ដា ២-លោក ឡូច នៃ

៣- លោក ជ៉ាលំ គិរម្យ ៤- វរសេនីយត្រី កែវ គួង

៥-លោក ឡុង គីមហុង ៦-លោកស្រី ជ៉ាន់ ដារីន

ង- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ចំពោះ

១- Mr. Lee, Jae Joon, ២- Mr. Joong-Yeon, Hwang

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ

១- លោក ហង់ ច័ន្ទរិទ្ធ ២- លោកស្រី ម៉ម ប៉ូរ៉ាម៉ាន់

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១០.១០២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩

លេខ:៩៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩
**អគ្គលេខាធិការរងគណៈរដ្ឋាភិបាល**
ស៊ុំ ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ

១- ឯកឧត្តម ហ៊ាង សុជាតិ
២-លោក ឈៀង សុភក្ត្រ
៣- លោក និត្យ ពិទ្ធ

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ

១- លោកជំទាវ ម៉ាន់ ណាទី
២- លោក ជ៉ីខ ផល្លា

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ

១- ឯកឧត្តម អ៊ុប សួនី
២- លោក ខាត់ ប៊ុណ្ណា
៣- លោក យឿត ធិន
៤- លោក សៅ ខ្សៀន

ឃ - គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ

១- ឯកឧត្តម លី សុខគីម
២- បណ្ឌិត នង សុខុម
៣- លោក គួល ចន្ថា
៤- លោកវរសេនីយទោ ម៉ៅ ច័ន្ទមង្គុិទ្ធ
៥- លោកវរសេនីយត្រី គង់ សុវណ្ណ
៦- លោកអនុសេនីយឯក មាស ឫទ្ធី
៧- លោកអនុសេនីយទោ សោម ម៉ានី
៨- លោក ស៊ិន សារ៉េត
៩- លោក ហ៊ឹម គិរី
១០- លោកវរសេនីយឯក យឿង ណារត
១១- លោកវរសេនីយ៍ត្រី លឹម ហុតលី
១២- លោកអនុសេនីយ៍ត្រី យូ សុពីរ
១៣- លោកជំទាវ ទ្រី អេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ៧.០៩១០.១០៧២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩

លេខ: ៩៣៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជីនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារ ជូនកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ ១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧ /០៥ ចុះថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១ /៤៥០ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៨៩ អនក្រ បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និង អនុក្រឹត្យលេខ ២០៤ អនក្រ បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្ស របស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើនប្រាក់ម្ហូបអាហារជូន កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ បក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្ស មូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្ស មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១-**

ប្រាក់បំណាច់មុខងារដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យលេខ ១៨៩ អនក្រ បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ ត្រូវកែប្រែប្រាក់បំណាច់មុខងារផ្តល់តាម អតីតភាព ដោយកាត់បន្ថយៈ

- ៥០ (ហាសិប) ភាគរយ លើមុខតំណែងជាមូលដ្ឋានពីលេខរៀង ១ (មួយ) ដល់លេខរៀង ១១ (ដប់មួយ) លើគ្រប់កម្រិតនៃអតីតភាព
- ៣០ (សាមសិប) ភាគរយ លើមុខតំណែងជាមូលដ្ឋានលេខរៀង ១២ (ដប់ពីរ) លើគ្រប់កម្រិត នៃអតីតភាព
- ០ (សូន្យ) ភាគរយលើមុខតំណែងជាមូលដ្ឋានពីលេខរៀង ១៣ (ដប់បី) ដល់លេខរៀង ១៦ (ដប់ប្រាំមួយ) លើគ្រប់កម្រិតនៃអតីតភាព ។

**មាត្រា ២-**

ប្រាក់បំណាច់មុខងារដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យលេខ ២០៤ អនក្រ បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ ត្រូវកែប្រែប្រាក់បំណាច់មុខងារ ដោយកាត់បន្ថយៈ

- ៥០ (ហាសិប) ភាគរយ លើមុខតំណែងជាមូលដ្ឋានពីលេខរៀង ១ (មួយ) ដល់លេខរៀង ១១ (ដប់មួយ) លើគ្រប់កម្រិត
- ៣០ (សាមសិប) ភាគរយ លើមុខតំណែងជាមូលដ្ឋានលេខរៀង ១២ (ដប់ពីរ) លើគ្រប់កម្រិត
- ០ (សូន្យ) ភាគរយលើមុខតំណែងជាមូលដ្ឋានពីលេខរៀង ១៣ (ដប់បី) ដល់លេខរៀង ១៦ (ដប់ប្រាំមួយ) លើគ្រប់កម្រិត ។

មាត្រា ៣-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ។

មាត្រា ៤ -

អនុក្រឹត្យនេះត្រូវចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ស្នើចុះហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ . ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ . ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក . ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក . ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក . ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១៦.០០០ លានរៀល (ដប់ប្រាំមួយពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៤ (បន្ទុកបុគ្គលិក) ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ឧបត្ថម្ភមួយលើកដំបូងជូនយោធិនប្រភេទ២ ដែលជាយោធិនពិការ ចំនួន ៩៩៨ នាក់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ -កាលប្បវត្តិ ✓

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១៨០ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦០៦/២៧៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណីយ និងការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅគ្រប់គ្រងការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី នៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណង ដូចតទៅ ៖

- បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ប្រកបដោយសុវត្ថិភាព
- ផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ទៅដល់ប្រជាជន អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់
- ការពារសុខភាពមនុស្ស សត្វ និងបរិស្ថាន ឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់ ដែលអាចបង្កដោយសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់
- សម្រួលចរាចរណ៍នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ មិនមានវិសាលភាពអនុវត្តចំពោះផលិតផលឱសថ ផលិតផលគ្រឿងសម្អាង ផលិតផលម្ហូបអាហារ សារធាតុគីមីបន្ថែមលើផលិតផលម្ហូបអាហារ និងផលិតផលជាសម្ភារៈប្រើប្រាស់ទាំងឡាយណាដែលនៅក្នុងលក្ខខណ្ឌធម្មតាពុំបង្កគ្រោះថ្នាក់ដល់សុខភាពអ្នកផលិត អ្នកដឹកជញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់។

**មាត្រា៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើនៅក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥.-**

ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៦.–**

ក្រសួង ស្ថាប័នដែលមានភារកិច្ចក្នុងការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ត្រូវចេញប្រកាស និងសារាចរណែនាំតាមភារកិច្ចទទួលខុសត្រូវរបស់ខ្លួន ដោយអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដើម្បីជំរុញការអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី៣
## វិធានការលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

**មាត្រា៧.–**

ការចាត់ថ្នាក់ភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ ។

**មាត្រា៨.–**

សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានបិទស្លាកសញ្ញាសារធាតុគីមីនៅលើសម្ភារៈវេចខ្ចប់ ដោយអនុលោមតាមប្រកាស និងសារាចរណែនាំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ។

ករណីលើកលែង ការដាក់ស្លាកសញ្ញាសារធាតុគីមី លើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់មួយចំនួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ចំពោះការដឹកជញ្ជូនសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមវិធាននៃការដឹកជញ្ជូនទំនិញដែលអាចបង្កគ្រោះថ្នាក់របស់អង្គការសហប្រជាជាតិ ហើយដែលតម្រូវឱ្យមានការដាក់ស្លាកសញ្ញា អំពីភាពអាចបង្កគ្រោះថ្នាក់នៅលើផ្ទៃខាងក្រៅនៃមធ្យោបាយដឹកជញ្ជូន ។

**មាត្រា៩.–**

ចំណុចសំខាន់ៗដែលតម្រូវឱ្យមាននៅក្នុងស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ មានជាអាទិ៍ ៖

- ព័ត៌មានអំពីផលិតផល
- រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់
- ពាក្យព្រមាន
- ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់

- ព័ត៌មានអំពីវិធានការបង្ការ ឬវិធីប្រើប្រាស់
- ព័ត៌មានអំពីផលិតករ ឬអ្នកផ្គត់ផ្គង់។

**មាត្រា១០.-**

ស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវមានលក្ខណៈដូចតទៅ ៖

- ងាយស្រួលអាន
- មើលឃើញច្បាស់
- មិនងាយរហែក ឬខូច
- មិនងាយបក ឬផ្តាច់ចេញពីសម្ភារៈវេចខ្ចប់
- មិនឆ្លកពណ៌ រលុបអក្សរ ឬរលុបរូបសញ្ញា។

**មាត្រា១១.-**

អក្សរដែលសរសេរលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និង ផលិតផលគីមីប្រើប្រាស់ ត្រូវអនុវត្តដូចខាងក្រោម ៖

ក. សម្រាប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលបាននាំចូលពីបរទេស ត្រូវមានបិទស្លាកសញ្ញាសារធាតុគីមីបន្ថែម ជាភាសាខ្មែរ មុនពេលចែកចាយ ឬយកទៅប្រើប្រាស់។

ខ. សម្រាប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលធ្វើការផលិត ឬវេចខ្ចប់ឡើងវិញនៅក្នុងស្រុក ត្រូវមានបិទស្លាកសញ្ញាសារធាតុគីមី ជាភាសាខ្មែរលើសម្ភារៈវេចខ្ចប់ មុនពេលដឹកចេញពីទីតាំងផលិត ឬវេចខ្ចប់ឡើងវិញ។

គ. ចំពោះចំណុចដែលមានលក្ខណៈទូទៅ ពាក់ព័ន្ធនឹងសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចជា ឈ្មោះពាណិជ្ជកម្ម ឈ្មោះគីមីទូទៅ អាចអនុញ្ញាតឱ្យប្រើជាភាសាអង់គ្លេសឬបារាំង នៅលើស្លាកសញ្ញាសារធាតុគីមី ដែលមានចែងក្នុងចំណុច ក និង ខ នៃមាត្រានេះ។

**មាត្រា១២.-**

ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវរៀបចំតាមលំដាប់រៀងនៃប្រភេទ និងកម្រិតនៃភាពអាចបង្កគ្រោះថ្នាក់របស់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

**មាត្រា១៣.-**

ទម្រង់និងពណ៌របស់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមី ដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមការកំណត់

នៃឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ។

ដោយឡែកទំហំនៃរូបសញ្ញាភាពអាចបង្កគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៤.-**

សារធាតុគីមីនិងផលិតផលគីមី ដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានភ្ជាប់ជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាព ដោយអនុលោមតាមប្រកាស និងសារាចរណែនាំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី។ ទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាព សម្រាប់សារធាតុគីមីនិងផលិតផលគីមី មានកំណត់ក្នុងឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យនេះ។

អក្សរដែលសរសេរក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវអនុវត្តដូចខាងក្រោម ៖

ក). សម្រាប់សារធាតុគីមី និងផលិតផលគីមីដែលបាននាំចូលពីបរទេស ត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពបន្ថែមជាភាសាខ្មែរ មុនពេលចែកចាយ ឬមុនយកទៅប្រើប្រាស់។

ខ). សម្រាប់សារធាតុគីមី និងផលិតផលគីមីដែលធ្វើការផលិត ឬវេចខ្ចប់ឡើងវិញនៅក្នុងស្រុក ត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពជាភាសាខ្មែរ មុនពេលដឹកចេញពីទីតាំងផលិត ឬវេចខ្ចប់ឡើងវិញ។

គ). ចំពោះចំណុចដែលមានលក្ខណៈទូទៅពាក់ព័ន្ធនឹងសារធាតុគីមី និងផលិតផលគីមី ដូចជាឈ្មោះពាណិជ្ជកម្ម ឈ្មោះគីមីទូទៅ អាចអនុញ្ញាតឱ្យប្រើជាភាសាអង់គ្លេសឬបារាំង នៅក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាពដែលមានចែងក្នុងចំណុច ក និង ខ នៃមាត្រានេះ។

**មាត្រា១៥.-**

ផលិតករដែលពាក់ព័ន្ធនឹងការផលិតសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- ដាក់ស្លាកសញ្ញាសារធាតុគីមីនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ
- រៀបចំឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមី ដូចមានចែងនៅក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ
- ផ្តល់ការបណ្តុះបណ្តាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការ បំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត។

**មាត្រា១៦.-**

អាជីវករដែលធ្វើអាជីវកម្មវេចខ្ចប់ឡើងវិញនូវសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- ដាក់ស្លាកសញ្ញាសារធាតុគីមី នៅលើសម្ភារៈវេចខ្ចប់ឡើងវិញនៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ
- ភ្ជាប់ឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមីដែលវេចខ្ចប់ឡើងវិញ ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ
- ផ្ដល់ការបណ្ដុះបណ្ដាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការបំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត។

**មាត្រា១៧.-**

ពាណិជ្ជករ ឬអ្នកចែកចាយសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- បិទបន្ថែមនូវស្លាកសញ្ញាសារធាតុគីមីលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលត្រូវធ្វើពាណិជ្ជកម្ម ឬចែកចាយនៅក្នុងប្រទេស ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ
- ភ្ជាប់បន្ថែមនូវឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមី ដែលត្រូវធ្វើពាណិជ្ជកម្ម ឬចែកចាយនៅក្នុងប្រទេស ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ
- ផ្ដល់ការបណ្ដុះបណ្ដាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការ បំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត។

**មាត្រា១៨.-**

និយោជកដែលទីតាំងរបស់ខ្លួនមានប្រើប្រាស់ ឬស្តុកសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ត្រូវ ៖

- រៀបចំចុះបញ្ជីសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលមាននៅក្នុងទីតាំងរបស់ខ្លួន
- រៀបចំបទបញ្ជាផ្ទៃក្នុងដើម្បីការពារសុវត្ថិភាព សុខភាពកម្មករ និងនិយោជិត និងបរិស្ថាននៅក្នុងទីតាំងរបស់ខ្លួន

- រៀបចំដាក់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ នៅកន្លែងស្តុកនិងបរិវេណប្រើប្រាស់ និងត្រូវបិទពាក្យព្រមានគ្រោះថ្នាក់ជាភាសាខ្មែរ
- ផ្តល់ការបណ្តុះបណ្តាលកម្មករ និយោជិត អំពីភាពអាចបង្កគ្រោះថ្នាក់ អំពីការការពារសុវត្ថិភាពក្នុងការប្រើប្រាស់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីការជួយសង្គ្រោះបឋម ក្នុងករណីមានគ្រោះថ្នាក់កើតឡើង និងអំពីការទប់ស្កាត់ការសាយភាយចូលទៅក្នុងបរិស្ថាន
- រៀបចំផែនការ បំពាក់ឧបករណ៍សង្គ្រោះបន្ទាន់ និងផ្គត់ផ្គង់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ សម្រាប់ការពារសុខភាព សុវត្ថិភាពកម្មករ និយោជិត ។

**មាត្រា១៩.-**

ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការដឹកជញ្ជូន ការនាំចូល ការស្តុកទុក ការលក់ដូរ និងការប្រើប្រាស់សារធាតុគីមី ផលិតផលគីមី ឬផលិតផលគីមីប្រើប្រាស់ ត្រូវមានដាក់ឬបិទស្លាកសញ្ញាសារធាតុគីមីនៅលើសម្ភារៈវេចខ្ចប់ ដូចមានចែងក្នុងមាត្រា៨ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ ។

**មាត្រា២០.-**

ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការដឹកជញ្ជូន ការនាំចូល ការស្តុកទុក ការលក់ដូរ និងការប្រើប្រាស់សារធាតុគីមី និងផលិតផលគីមី ត្រូវមានភ្ជាប់មកជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាព ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៤
## ទណ្ឌកម្មរដ្ឋបាល

**មាត្រា២១.-**

ផលិតករ អាជីវករ ពាណិជ្ជករ និយោជក អ្នកនាំចូល អ្នកចែកចាយ រូបវន្តបុគ្គល និងនីតិបុគ្គលផ្សេងទៀត ដែលមិនអនុវត្តតាមវិធានការ ដូចមានចែងនៅក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា២២.-**

ក្នុងករណីដែលពុំអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ ផលិតករ អាជីវករ ពាណិជ្ជករ និយោជក អ្នកនាំចូល អ្នកចែកចាយ រូបវន្តបុគ្គល និងនីតិបុគ្គលផ្សេងទៀត ត្រូវទទួលចំណាត់វិធានការរដ្ឋបាលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា២៣.-**

ការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី នៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុវត្តពេញលេញក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។

# ជំពូកទី៦
# អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៧ ឆ្នាំ ២០០៩**

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

## ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ

- ឯកសារបទដ្ឋានបច្ចេកទេស ស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី (Globally Harmonized System of Classification and Labelling of Chemicals) សំដៅដល់ឯកសារដែលបានរៀបចំ និងបោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ សម្រាប់ណែនាំក្របខណ្ឌបច្ចេកទេសឱ្យមានការឯកភាពគ្នាជាសកល ក្នុងការអនុវត្តការចាត់ថ្នាក់ភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ព្រមទាំងការផ្តល់ព័ត៌មាន អំពីភាពអាចបង្កគ្រោះថ្នាក់ទៅដល់គ្រប់បណ្តាភាគីពាក់ព័ន្ធ តាមរយៈស្លាកសញ្ញាសារធាតុគីមី និងតាមរយៈឯកសារព័ត៌មានអំពីសុវត្ថិភាព។

- សារធាតុគីមី (Chemical Substances) សំដៅដល់ធាតុគីមី និងសមាសធាតុរបស់វា ដែលមាននៅក្នុងធម្មជាតិ ឬបានមកពីដំណើរការផលិតកម្ម រួមទាំងសារធាតុបន្ថែមដែលចាំបាច់ ដើម្បីរក្សាឱ្យមានស្ថិរភាពនូវផលិតផល ព្រមទាំងសារធាតុមិនសុទ្ធ ដែលទាញយកចេញពីដំណើរការផលិតកម្ម តែមិនរាប់បញ្ចូលសារធាតុរំលាយដែលអាចធ្វើការញែកចេញបាន ដោយមិនធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃសារធាតុគីមី ឬមិនធ្វើឱ្យប្រែប្រួលនូវធាតុបន្សំរបស់វា។

- ផលិតផលគីមី (Chemical Products) សំដៅដល់ល្បាយឬសូលុយស្យុង ដែលផ្សំឡើងដោយសារធាតុគីមីចំនួន ២ ឬច្រើនមុខដែលពុំមានប្រតិកម្មគីមីនឹងគ្នា។

- ផលិតផលគីមីប្រើប្រាស់ (Chemical Consumer Products) សំដៅដល់សារធាតុគីមី និងផលិតផលគីមីដែលមានលក្ខណៈជាផលិតផលសម្រេច ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ហើយត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃជីវភាពរស់នៅ ។

- ស្លាកសញ្ញាសារធាតុគីមី (Chemical Label) សំដៅដល់ព័ត៌មានសង្ខេបអំពីសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ អំពីភាពអាចបង្កគ្រោះថ្នាក់ អំពីការណែនាំសុវត្ថិភាពក្នុងការដឹកជញ្ជូន ថែរក្សា ស្តុក ប្រើប្រាស់ វិធានការបង្ការ និងព័ត៌មានដែលពាក់ព័ន្ធនឹងប្រភពផលិតនិងចែកចាយក្នុងទម្រង់ជារូបភាព និងអក្សរដែលបិទភ្ជាប់លើសម្ភារៈវេចខ្ចប់។

- ព័ត៌មានអំពីផលិតផល (Product Identifier) សំដៅដល់ព័ត៌មានអំពីអត្តសញ្ញាណរបស់ផលិតផល រួមមានឈ្មោះផលិតផលដែលមានឈ្មោះពាណិជ្ជកម្ម និងឈ្មោះគីមីទូទៅ ធាតុផ្សំសំខាន់ៗ បរិមាណ ពាណិជ្ជសញ្ញា លេខសម្គាល់អន្តរជាតិ កាលបរិច្ឆេទផលិត និងកំណត់កាលប្រើប្រាស់។

- រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ (Hazards Pictogram) សំដៅដល់រូបភាពដែលបញ្ជាក់សញ្ញានៃភាពអាចបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលមានកំណត់ក្នុង ឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យនេះ ។

- ពាក្យព្រមាន (Signal Word) សំដៅដល់ពាក្យអត្ថាធិប្បាយសង្ខេប អំពីកំរិតនៃភាពអាចបង្កគ្រោះថ្នាក់ ជាការរំលឹកបន្ទាន់ដល់អ្នកអានស្លាកសញ្ញា ពីសក្តានុពលនៃភាពអាចបង្កគ្រោះថ្នាក់ ដែលជាទូទៅប្រើពាក្យ " ប្រុងប្រយ័ត្ន" និងពាក្យ " គ្រោះថ្នាក់ " ។

- ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ (Hazard Statement) សំដៅដល់ព័ត៌មានដែលបង្ហាញអំពីប្រភេទ និងកម្រិតបង្កគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ។

- ព័ត៌មានអំពីវិធានការបង្ការ (Precautionary Statements) សំដៅដល់ព័ត៌មានដែលបញ្ជាក់សកម្មភាពចាំបាច់ ដើម្បីបង្ការឬកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ ដែលបង្កឡើងដោយភាពអាចបង្កគ្រោះថ្នាក់ នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ក្នុងពេលផលិត ដឹកជញ្ជូន ចែកចាយ ប្រើប្រាស់ ។ល។

- ព័ត៌មានអំពីផលិតករ ឬអ្នកផ្គត់ផ្គង់ (Producer or Supplyer Identifier) សំដៅដល់ព័ត៌មានអំពីក្រុមហ៊ុនផលិត ឬក្រុមហ៊ុនចែកចាយសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដែលរួមមានឈ្មោះក្រុមហ៊ុន និងអាសយដ្ឋានទំនាក់ទំនង ។

## ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

## ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

### ចំណាត់ថ្នាក់ភាពបង្គគ្រោះថ្នាក់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់

១). ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ជាលក្ខណរូប

| ល.រ | ប្រភេទបង្កគ្រោះថ្នាក់ជាលក្ខណរូប |
|---|---|
| ១ | សារធាតុផ្ទុះ |
| ២ | ឧស្ម័នងាយឆាបឆេះ |
| ៣ | ចំហាយងាយឆាបឆេះ |
| ៤ | ឧស្ម័នឆេះផ្ទុះ |
| ៥ | ឧស្ម័នក្រោមសម្ពាធខ្ពស់ |
| ៦ | សារធាតុរាវងាយឆាបឆេះ |
| ៧ | សារធាតុរឹងងាយឆាបឆេះ |
| ៨ | សារធាតុងាយមានប្រតិកម្មដោយខ្លួនឯង |
| ៩ | សារធាតុរាវដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់ ៥ នាទី |
| ១០ | សារធាតុរឹងដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់ ៥ នាទី |
| ១១ | សារធាតុដែលឆេះដោយខ្លួនឯង |
| ១២ | សារធាតុដែលប៉ះនឹងទឹកប្លែងទៅជាឧស្ម័នឆាបឆេះ |
| ១៣ | សារធាតុរាវឆេះផ្ទុះ |
| ១៤ | សារធាតុរឹងឆេះផ្ទុះ |
| ១៥ | សារធាតុពែអុកស៊ីតសរីរាង្គ |
| ១៦ | សារធាតុបង្កច្រេះស៊ីលោហៈ |

២). ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ដោយផ្ទាល់ដល់សុខភាព

| ល.រ | ប្រភេទបង្កគ្រោះថ្នាក់ដល់សុខភាព |
|---|---|
| ១ | ពុលធ្ងន់ធ្ងរ |
| ២ | រលាកស្បែក |
| ៣ | រលាកភ្នែកធ្ងន់ធ្ងរ |
| ៤ | មានជំងឺប្រតិកម្ម ឬប្រតិកម្មស្បែក |
| ៥ | ធ្វើឱ្យខូចកោសិកា |
| ៦ | កើតមហារីក |
| ៧ | មានគ្រោះថ្នាក់ដល់ការបង្កកំណើត ទារក និងកុមារ |
| ៨ | បំពុលសរីរាង្គជាក់លាក់មួយពេលទទួលរងសារធាតុគីមីមួយដង |
| ៩ | បំពុលសរីរាង្គជាក់លាក់មួយពេលទទួលរងសារធាតុគីមីច្រើនដង |
| ១០ | ធ្វើឱ្យខូចប្រព័ន្ធផ្លូវដង្ហើម |

៣). ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក

| ល.រ | ប្រភេទបង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក |
|---|---|
| ១ | បំពុលធ្ងន់ធ្ងរបរិស្ថានទឹក |
| ២ | ធ្វើឱ្យមានការកកផ្តុំក្នុងបរិមាណច្រើន |
| ៣ | ធ្វើឱ្យមានការបំបែកសារធាតុគីមីសរីរាង្គក្នុងបរិមាណច្រើន |
| ៤ | បំពុលរ៉ាំរ៉ៃទូវជីវិតក្នុងបរិស្ថានទឹក |

ឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

### រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់

| | | |
|---|---|---|
|  សញ្ញាបង្កការឆាបឆេះ |  សញ្ញាបង្កការឆេះ ឬបង្កឱ្យមានអុកស៊ីតកម្ម |  សញ្ញាបង្កការផ្ទុះ |
|  សញ្ញាបង្កការរលាកឬច្រេះស៊ី |  សញ្ញាបំពង់ដាក់ឧស្ម័នបណ្ណែន |  សញ្ញាបង្កគ្រោះថ្នាក់ដល់ស្លាប់ |
|  សញ្ញាឱ្យប្រុងប្រយ័ត្ន |  សញ្ញាបង្កគ្រោះថ្នាក់ដល់បរិស្ថាន |  សញ្ញាបង្កគ្រោះថ្នាក់ដល់មនុស្ស |

ឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

## ស្តីពី

## ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមី និងផលិតផលគីមី

| ល.រ | ចំណុចសំខាន់ៗត្រូវបរិយាយក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព |
|---|---|
| ១ | ព័ត៌មានអំពីផលិតផលនិងអ្នកផ្គត់ផ្គង់ |
| ២ | ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ |
| ៣ | ព័ត៌មានអំពីធាតុបន្សំនៃផលិតផល |
| ៤ | វិធានការសង្គ្រោះបឋម |
| ៥ | វិធានការបង្ការអគ្គិភ័យ |
| ៦ | វិធានការបង្ការការសាយភាយ |
| ៧ | ការប្រើប្រាស់ និងស្តុក |
| ៨ | ការការពារសុវត្ថិភាពកម្មករ |
| ៩ | លក្ខណរូប និងលក្ខណៈគីមីផលិតផល |
| ១០ | លំនឹង និងប្រតិកម្ម |
| ១១ | ព័ត៌មានអំពីពុកស៊ីកូឡូស៊ី |
| ១២ | ព័ត៌មានអំពីឥទ្ធិពលទៅលើអេកូឡូស៊ី |
| ១៣ | ការគិតគូរពីការបោះបង់ចោល |
| ១៤ | ព័ត៌មានអំពីសុវត្ថិភាពដឹកជញ្ជូន |
| ១៥ | ព័ត៌មានអំពីបញ្ញត្តិច្បាប់ត្រួតពិនិត្យ |
| ១៦ | ព័ត៌មានផ្សេងៗ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១៩១ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្ដីពីការត្រួតពិនិត្យថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រង ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងជាអាទិ៍ ៖

- ការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- បង្កើនប្រសិទ្ធភាពលើការត្រួតពិនិត្យកញ្ចប់បារី
- កាត់បន្ថយការប្រើប្រាស់ថ្នាំជក់
- អប់រំផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើកញ្ចប់បារីគ្រប់ប្រភេទ ដែលចែកចាយនិងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

- កញ្ចប់បារី សំដៅដល់ប្រអប់ទាំងឡាយ ក្រដាស គ្រឿងរុំពីក្រៅ ឬអ្វីៗសម្រាប់ដាក់បារី
- សារព្រមានសុខភាព សំដៅដល់សារជាភាសាខ្មែរ ដែលបោះពុម្ពលើកញ្ចប់បារី បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥.-**

ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី ដូចមានចែងក្នុងជំពូកទី ៣ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការណែនាំ និងត្រួតពិនិត្យរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី៣

## វិធានការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី

**មាត្រា៦.-**

បារីដែលផលិតក្នុងស្រុក ឬនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរលើកញ្ចប់បារី ស្តីពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ ។

សារព្រមានសុខភាពត្រូវតែងាយអាន ងាយមើល ជាក់ច្បាស់ មិនឆ្លកពណ៌ មិនរលុបអក្សរ ។

**មាត្រា៧.-**

ទំហំនិងទីតាំងនៃសារព្រមានសុខភាព ដែលត្រូវបោះពុម្ពលើកញ្ចប់បារី ត្រូវឆ្លើយតបនឹងលក្ខណៈពិសេសដូចខាងក្រោម ៖

- សារព្រមានសុខភាព ត្រូវមានទំហំ ៣០ (សាមសិប) ភាគរយយ៉ាងតិច
- សារព្រមានសុខភាព ត្រូវបោះពុម្ពលើផ្ទៃសំខាន់ ទាំងសងខាង ។

**មាត្រា៨.-**

គំរូសារព្រមានសុខភាពស្របតាមមាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យនេះ និងរបៀបនៃការផ្លាស់ប្តូរគំរូសារព្រមានសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី៤

## ទណ្ឌកម្ម

**មាត្រា៩.-**

ផលិតករក្នុងស្រុក អ្នកនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់ ដែលមិនគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកការប្រកបអាជីវកម្មជាបណ្តោះអាសន្ន
- បិទអាជីវកម្មជាស្ថាពរ ក្នុងករណីមិនរាងចាល ។

ចំពោះការផ្អាកការប្រកបអាជីវកម្មជាបណ្តោះអាសន្ន និងការបិទអាជីវកម្មជាស្ថាពរ ត្រូវសុំការយល់ព្រមជាមុនពីប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា១០.-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ផលិតករក្នុងស្រុក និងអ្នកនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានរយៈពេល ៩ (ប្រាំបួន) ខែ សម្រាប់បោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរលើកញ្ចប់បារី ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃ កងយោធពលខេមរភូមិន្ទ ជូន ឧត្តមសេនីយ៍ទោ **ឡោក ឃួរ** អត្តលេខ ០១១០០៥ បច្ចុប្បន្នទៅបំរើការងារក្នុងក្របខ័ណ្ឌ អគ្គស្នងការនគរបាលជាតិ នៃ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តា សមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៥៤២ អនក្រ.តត

# អនុក្រឹត្យ

# ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១:** ត្រូវបានតែងតាំងលោកស្រី **ចាប ស៊ីអ៊ុយ** ជាទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៤៣ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតែងតាំងលោកវរសេនីយ៍ឯក **ពិន ឆាំង** អត្តលេខ ០០៣៩៥៥ ជាជំនួយការប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ១០ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានផ្ទេរភារកិច្ចឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡាយ គីមលី** អត្តលេខ ៦៥៥៦៦ ពីប្រធាននាយកដ្ឋានអនុវត្តច្បាប់ ទៅជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តនីអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១០ ឆ្នាំ ២០០៩ .

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានដំឡើងថ្នាក់**តាមវេន**ជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌ**មន្ត្រីគ្រប់គ្រងរដ្ឋបាល**របស់ក្រសួង ស្ថាប័ន គិតចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០០៩** តទៅ ដូចមានរាយនាមខាងក្រោម :

| **ក្រសួងអប់រំ យុវជន និងកីឡា** | | | | |
|---|---|---|---|---|
| ១ | **ញឹម វ៉ាន់ច័ន្ទកន** | ស | ពីវរមន្ត្រី ថ្នាក់លេខ **២** | ទៅវរមន្ត្រី ថ្នាក់លេខ **១** |
| ២ | **យ៉ែម ឧត្តម** | ប | ពីវរមន្ត្រី ថ្នាក់លេខ **២** | ទៅវរមន្ត្រី ថ្នាក់លេខ **១** |
| ៣ | **វ័ន្ត សុខា** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅវរមន្ត្រី ថ្នាក់លេខ **២** |
| ៤ | **ទ្រឹង លីមស្រ៊ី** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅវរមន្ត្រី ថ្នាក់លេខ **២** |
| ៥ | **គី ឆួច** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅវរមន្ត្រី ថ្នាក់លេខ **២** |
| ៦ | **ថោង ប៊ុវ៉ាន់** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅវរមន្ត្រី ថ្នាក់លេខ **២** |
| ៧ | **ម៉ែន សារឿន** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅវរមន្ត្រី ថ្នាក់លេខ **២** |
| ៨ | **សំ សេរីរតន៍** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅវរមន្ត្រី ថ្នាក់លេខ **៣** |
| ៩ | **យ៉ង យ៉ារណ្ណ** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅវរមន្ត្រី ថ្នាក់លេខ **៣** |
| ១០ | **លី សន្ធិ** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅវរមន្ត្រី ថ្នាក់លេខ **៣** |
| ១១ | **នេត ធារ៉ុម** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅវរមន្ត្រី ថ្នាក់លេខ **៣** |
| ១២ | **ម៉ាន់ សុមេធ** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅវរមន្ត្រី ថ្នាក់លេខ **៣** |
| ១៣ | **ឡោ សុជាតិ** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៦** | ទៅវរមន្ត្រី ថ្នាក់លេខ **៥** |

| | | | | |
|---|---|---|---|---|
| ១៤ | ឡាយ បូរិន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ១៥ | ឡិម សិទ្ធី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៦ | សេង ប៊ុនធឿន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៧ | ច័ន្ទ រ័ត្ន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ១៨ | អ៊ុន ច័ន្ទស៊ីយ៉ាឧត្តុង្គ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ក្រសួងកិច្ចការនារី | | | | |
| ១ | យស សាខន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ២ | ហេង ស៊ីថុន | ស | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣ | ឡិក ភនធឿន | ស | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ៤ | ជួង វឌ្ឍនី | ស | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ៥ | ឡុង និមល | ស | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ៦ | ជុត លាងវ៉ាន់នី | ស | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៧ | ជិន ស៊ីវ៉េត | ស | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៨ | ខៀវ សិរីវឌ្ឍនា | ស | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៩ | ឡី រ៉ានី | ស | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ១០ | សុខ មុនី | ស | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ១១ | ញាណ សុចិត្រា | ស | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ១២ | ហ៊ូ និមិត្តា | ស | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ១៣ | សៅ វណ្ណសិរីវុឌ្ឍ | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | | | | |
| ១ | ស្រី សួន | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅវរមន្ត្រី ថ្នាក់លេខ ១ |
| ២ | អ៊ឹម គីមលន | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅវរមន្ត្រី ថ្នាក់លេខ ១ |
| ៣ | លន់ សាវី | ស | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៤ | ម៉ៅ កេង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៥ | ព្រុំ សំអាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៦ | ឡុង ឧត្តម | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៧ | ដែក សារិន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨ | ស៊ុន សុវណ្ណនី | ស | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៩ | ច័ន្ទ វណ្ណា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ក្រសួងយុត្តិធម៌ | | | | |
| ១ | គុង ពាវ | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅវរមន្ត្រី ថ្នាក់លេខ ១ |

| | | | | |
|---|---|---|---|---|
| ២ | ឡឿង នាយ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៣ | កែវ សុផល | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៤ | ច័ន្ទ មនោ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥ | ស៊ឹម ឫទ្ធីសែន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦ | អ៊ុច ហ៊ីង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៧ | អ៊ុ រ៉ាស៊ី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៨ | ប៊ុនយ៉ៃ ណារិន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៩ | ផ្លុង ពិសិដ្ឋ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ក្រសួងបរិស្ថាន | | | | |
| ១ | សំ ខាន់នី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ២ | អៀង ចិត្រា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ៣ | ទង់ ឆេងគង់ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ៤ | កុច សុទាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៥ | ម៉េង សាធុង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៦ | នេព ផល្លា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៧ | ចាយ សាមិត្ត | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៨ | ជឹម រដ្ឋា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៩ | ជួន ច័ន្ទរិទ្ធី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | | | | |
| ១ | ម៉ែន សុចិត្រ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ២ | អ៊ុក សមវិទ្យា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ៣ | ហែម ចន្ថា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | | | | |
| ១ | ង៉ោ ជូ | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | | | | |
| ១ | ប៊ិន សារ៉េត | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅវរមន្ត្រី ថ្នាក់លេខ ១ |
| ២ | ឆិត សំអឿន | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅវរមន្ត្រី ថ្នាក់លេខ ១ |
| ៣ | ឡៅ នី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៤ | ឈយ គឹមស៊ឿន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៥ | ញ៉ឹប ច័ន្ទថេត | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៦ | កៅ ផល់ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |

| | | | | |
|---|---|---|---|---|
| ៧ | ឡោ ស្មើ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨ | ផាត់ មុនី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៩ | សៅ សំបូរ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១០ | ខឹម ចិន្តា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១១ | កែវ សេង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១២ | សំ សារិន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៣ | យិន សុខ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៤ | ជួង សុផល | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៥ | អេង ប៊ុនហ៊ាង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៦ | គិត សេង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៧ | ផាត់ លេង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៨ | ហេង វិសាល | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៩ | យិន ឡាត់ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០ | ម៉ើន សារុម | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ពីវរមន្ត្រី ថ្នាក់លេខ ៥ |
| ២១ | ទោ ប៊ុនថាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២២ | ឌួង ប៊ុននី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២៣ | ហ៊ាន ប៊ុនធឿន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២៤ | ប៉ែន ទុជ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២៥ | អ៊ុក ស៊ីផាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២៦ | សាន វណ្ណធី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២៧ | អ៊ុម ចាន់ថុល | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២៨ | ឈុំ គិតលន់ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២៩ | វន មុនិន្ទ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៣០ | ឈូក បូរិន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៣១ | ហ៊ួត ប៊ុនណារី | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ៣២ | សូ ខនឫទ្ធិគុណា | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | | | | |
| ១ | ម៉ួង ណាល់ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ២ | ជួង ហុង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |
| ៣ | មាស ឈាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅវរមន្ត្រី ថ្នាក់លេខ ២ |

| | | | | |
|---|---|---|---|---|
| ៤ | អៀម យាង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៥ | ម៉ៅ សុវត្ថិ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៦ | ជុំ សៀកខួន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧ | ឃួន វ៉ានីន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៨ | សៀង សុខឃុនឌី | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| **ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | | | | |
| ១ | ស៊ឹម អៀង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ២ | ខាង សារឿន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |

**មាត្រា ២ :** ត្រូវបានដំឡើងថ្នាក់**តាមវេន**ជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌ**មន្ត្រីសុខាភិបាលជាន់ខ្ពស់** របស់ក្រសួង**សុខាភិបាល** គិតចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០០៩** តទៅ ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | ឌួង សុជាតិ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៤ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៣ |
| ២ | ជា ឈីវស្រួង | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៥ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៤ |
| ៣ | សុខ ទូច | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៦ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៥ |
| ៤ | ញ៉ៀម ធួក | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៦ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៥ |
| ៥ | ច ម៉េងចូ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៧ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៦ |
| ៦ | ជិន ឈាង | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧ |
| ៧ | ជី មានហៀ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧ |
| ៨ | តាន់ ទូចឆេង | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៩ | សាន់ សារី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១០ | ឡូ វាសនាគិរី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |

| | | | | |
|---|---|---|---|---|
| ១១ | ខាត់ សុផល | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១២ | យក់ សម្បត្តិ | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៣ | ហ៊ី សុប្រាតា | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៤ | ឡៅ ស៊ុនថារ៉េត | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៥ | សេង តីរក្ស | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៦ | សោម វណ្ណឫទ្ធី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៧ | អ៊ុំ សុខុម | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៨ | គង់ សន្យា | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៩ | យឹត ស៊ុនណារ៉ុង | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២០ | ញៀម សុគៀន | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២១ | គង់ តីរម្យ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៩ |
| ២២ | សារ៉ាក់ ផល្លី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៣ | ឌី ម៉េតសុឫទ្ធី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៤ | ច័ន្ទ សំឡេង | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៥ | ជឹង ប្រាមោទ្យ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |

| | | | | |
|---|---|---|---|---|
| ២៦ | សុខ ប៊ូរី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៧ | អ៊ុង ចក្រាវុធ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៨ | ឈយះ ណារ៉េត | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៩ | អ៊ុក ធីរោ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣០ | ជា សាវុធ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣១ | ម៉ម ប៊ុនសុជាតិ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣២ | តាន់ សុគន្ធ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣៣ | សុខ ប៊ុនថា | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣៤ | ដួង ឆាយ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
